# ផលិតកម្មដំណាំឪឡឹក

## ១-ស្ថានភាពដំណាំឪឡឹក

- ឪឡឹក មានដើមកំណើតនៅ ទ្វីបអាហ្វ្រិកខាងត្បូង
- ឪឡឹកគេចែកជា៤ប្រភេទ:

. Citrullus Lanatus

. Citrullus Colocynthis L

. Citrullus Ecirrhosus cogn

. Citrullus Naudinianus(sond)

# តើឪឡឹកស្ថិតនៅក្នុងគ្រួសារអ្វី?

## ២-ចំណាត់ថ្នាក់ដំណាំឪឡឹក

- ស្ថិតក្នុងគ្រួសារ Cucurbitaceae
- លំដាប់ Citrullus
- ឈ្មោះវិទ្យាសាស្ត្រ Citrullus Lanatus
- ឈ្មោះជាភាសាអង់គ្លេស Watermelon

- ដើម
- ស្លឹក
- ប្រព័ន្ធឫស
- ផ្កាៈ មានផ្កាញី និងផ្កាឈ្មោលដាច់ពីគ្នា ការបង្កកំណើតធ្វើឡើងនៅពេលព្រឹកចាប់ពីម៉ោង៧-១១
- ផ្លែ

# ៣-កត្តាសំខាន់ៗសំរាប់ដំណាំឪឡឹកមាន

## -សីតុណ្ហភាព

.វាត្រូវការពន្លឺថ្ងៃពី ១0-១២ម៉ោងសំរាប់ធ្វើរស្មីសំយោគ

.វាអាចដុះលូតលាស់បាន សីតុណ្ហភាពពី ១៥-៣៥ oC

.ដំណាក់កាលដុះពន្លក ២0-២២ oC

.ពេលចេញផ្កា ២៤-២៧ oC និងវគ្គទុំ ២៧-៣0 oC

.ពេលយប់ឃួរ ២0-២៤ oC ពេលថ្ងៃល្មម ២៥-៣0 oC

-កត្តាដី

. ប្រភេទដីល្បាយខ្សាច់

. ដីល្បាប់

. ដីក្រហមភ្នំភ្លើង

. Phដីពី ៥-៦,៨

-របបខ្យល់ សំណើម និងទឹកភ្លៀង

.វាត្រូវការរបបខ្យល់ខ្សោយ

.ដុះលូតលាស់បានល្បឿនទូវសំណើម ៧៥-៨៥%

.បើសំណើមចុះទាបពី៤៥-៥៥%ដុះលូតលាស់មិនល្អ

.វាត្រូវការសំណើមជាមធ្យមពី៨០-៨៥%

.របបទឹកភ្លៀងល្អរយៈពេល៣ខែពី ១២០-១៨០មម

# ៤-បច្ចេកទេសដាំដុះ

# -ការជ្រើសរើសពូជ

ពូជដែលល្អអាចយកមកដាំដុះបានមានពាក្រុមហ៊ុនៈ

.ក្រុមហ៊ុន Chea tai ឈ្មោះពូជ Summer

.ក្រុមហ៊ុនTakii seed ឈ្មោះពូជNew Dragon

.ក្រុមហ៊ុនKnown Youឈ្មោះពូជNew Dragon

## -ការជ្រើសរើសពូជយកមកដាំត្រូវពិនិត្យអំពី

-ថ្ងៃ ខែ ឆ្នាំ ផលិត

-ភាគរយនៃដំណុះ

-អាយុកាលរបស់ពូជ

## -ការរៀបចំដី

.ភ្ជួររាស់ដី២-៣លើក

.ហាលដីឱ្យបានយូរ

.ហាមមិនឱ្យដាំឪឡឹកបន្ទាប់ពីដាំដំណាំ ត្រសក់ ល្ពៅ ត្រឡាច ម្រះ ឃ្លោក និងននោង ។

.ការរៀបចំដីវាក៏អាស្រ័យទៅនិងប្រភេទដីផងដែរ

.ប្រភេទដីល្បាប់គេភ្ជួរក្រោយពេលទឹកស្រករយៈពេល ១០-១៥ថ្ងៃ

.ដីនៅតំបន់មួយចំនួនទៀតគេដាំបន្ទាប់ពីធ្វើស្រូវដោយមិនចាំបាច់ភ្ជួរ គ្រាន់តែកាប់រណ្តៅដាំ

.កន្លែងខ្លះគេគ្រាន់តែភ្ជួរទុកឱ្យមានគល់ជញ្ជ្រាំង និងដីអាចម៍បំណាស់ ។

## -របៀបដាំដុះ

.ការដាំដោយគ្រាប់ផ្ទាល់

*ការកាប់រណ្ដៅដាំ: លើករងទទឹងចន្លោះ ១២0-១៥0ស.ម

*កាប់រណ្ដៅលើរងជំរៅ៨-១0ស.ម

*ចន្លោះគុម្ព១២0ស.ម

*ដាក់ជីលាមសត្វ និងជី ១៥.១៥.១៥ ចំនួន៤0ក្រ ក្នុង១0រណ្ដៅ

*គ្រាប់ពូជត្រូវហាលថ្ងៃឱ្យក្តៅរួចយកត្រាំទឹកក្តៅឧណ្ហៗ (៣0-៣៥អង្សាសេ) រយៈពេល១៥នាទី

*លាងសំអាតគ្រាប់រួចផ្អាប់១យប់

*យកថ្នាំ Maneb លាយគ្រាប់រួចយកទៅដាំ

*ដាំចំនួន៣គ្រាប់ក្នុង១រណ្តៅ បាតរណ្តៅដាក់ថ្នាំ Furadan បន្តិច

- គ្របកំណាត់ចំបើងខ្លីៗហើយស្រោចទឹកឱ្យជោគ
- ៦ថ្ងៃក្រោយដាំយកថ្នាំផ្សិត Kinalux ២៥ សេសេ លាយទឹក៨លីត្របាញ់ពេលល្ងាចត្រជាក់ ។

.ការដាំដោយបណ្តុះកូនៈ

- ប្រើកន្ទោង ឬថង់ដើម្បីបណ្តុះ

- ផ្សំដីដែលមានជីជាតិហើយស្ងួត ជាមួយផេះអង្កាម១ភាគ ស្រកីដូង១ភាគ សរុបទំងន់ ១០០គ.ក្រ លាយជីផូស្វាត ឬDAPចំនួន ១-១,៥គក្រ ឬជី ១៥.១៥.១៥ ចំនួន ២គក្រ ថ្នាំ Furadan 3Hចំនួន២ខាំលាយឱ្យសប់
- យកដីទៅច្រកថង់ ឬកន្ទោង២/៣នៃកំពស់
- យកគ្រាប់ដែលបានធ្វើប្រព្រឹត្តិកម្មរួចមកបណ្តុះ

- ដាក់គ្រាប់៣-៤គ្រាប់លប់ដីបំពេញ
- គ្របចំបើងរយៈពេល២ថ្ងៃ ស្រោចទឹក២ដងក្នុង១ថ្ងៃ
- យកចំបើងចេញ ៥ថ្ងៃ យកទៅដាំបាន

-ការស្រោចស្រព:

- គេដាំវាដោយយកសំណើមពីដី
- ពេលចេញផ្កាវាត្រូការសំណើមដី ៦៥-៧0% បើប្រើវិធីបញ្ចូលទឹកគឺ ២ដង/អាទិត្យ

- ពេលចាប់ផ្តើមចេញផ្កាដល់ផ្លែទំហំ៥-៦ស.ម ពេលនោះវាមានដៃ១គូរអមទងផ្លែស្ងួត គេត្រូវរក្សាសំណើមដីពី ៨0-៨៥%

-ការជ្រុំជ្រោយដីៈ

- ធ្វើឡើងក្រោយដាំ១៥-១៧ថ្ងៃ កូនឪឡឹកមានស្លឹកពិត៦-៧សន្លឹក
- កាត់ស្លឹចំនួន៣ ហើយកប់ទងទៅក្នុងដី ជ្រុំជ្រោយដីពូនឡើង

-ការដាក់ជី

.ជីកំប៉ុស្ត ៧-១០តោន/ហ.ត ទ្រាប់បាត

.ជី ១៥.១៥.១៥ ចំនួន២០០គក្រ ទ្រាប់បាត

.ជីបំប៉នអ៊ុយរ៉េ ៥០គក្រ លាយទឹកស្រោច១០ថ្ងៃ ក្រោយដាំ

.ជីបំប៉ន១៥.១៥.១៥ចំនួន១៥០គក្រ លាយជី DAP ចំនួន១០០គក្រដាក់ចន្លោះគុម្ព ឬជុំវិញគល់ ក្រោយដាំរយៈពេល២៥ថ្ងៃ

.បំប៉នចុងក្រោយជីប៉ូតាស ៨០គក្រ ក្រោយពីដាំ ៤៥ថ្ងៃ ដល់ ៥០ថ្ងៃ

# ៥-សត្វល្អិត ជំងឺ និងកត្តាចង្រៃផ្សេងៗ

## -សត្វល្អិត

.ពួកជញ្ជក់ៈ

- ចៃ
- មមាច
- មមង់
- រុយស

.ពពួកកាត់ស្លឹក និងដើមៈ

- ដង្កូវហ្វូង
- ដង្កូវចោះផ្លែ
- ដង្កូវស៊ីផ្កា
- ដង្កូវកាត់ដើម
- ដង្កូវមូរស្លឹក និង
- ដង្កូវរុលក្នុងស្លឹក

## -វិធានការការពារ និងកំចាត់

.កំចាត់ស្មៅ កាត់ស្លឹក ចំណុះដើមសមស្រប

.ការជ្រើសរដូវសមស្រប

.ជ្រើសរើសពូជធន់ អាយុកាលខ្លី

.ប្រើថ្នាំ Monocrotophos ដូចជា: Azodrin DiazinonMevinphos បាញ់១សប្តាហ៍ម្តងនៅពេលពិនិត្យឃើញមេចំណាស់របស់វា (បាញ់ថ្នាំពេលល្ងាចត្រជាក់)

## -ជំងឺសំខាន់ៗ

.ក្រុមបង្កដោយវីរុស

- វីរុសបង្កអោយរួញត្រួយ: Papaya Ring Sport  Virus
- វីរុសបង្កអោយរួញស្លឹក: Watermelon Mosaic

ជំងឺទាំងពីរនេះបង្កឡើងដោយ ចៃខ្មៅ និងចៃបៃតង

## -ជម្ងឺដែលបង្កដោយរោគផ្សិត

.ផ្សិតបង្កអោយរលួយកូន មានឈ្មោះហៅថា Damping-off បង្កដោយមេរោគ ៣ប្រភេទគឺ ៖ Rhizoctoniasolani Phithium spp and Cercospora spp

.ផ្សិតបង្កអោយពុកឫស: មានឈ្មោះហៅថា Fasarium Wilt បង្កដោយ Fusarium Osysporum f.sp.neverm



Maladie des racines liégeuses



Maladie de la pourriture des racines



Nématode des racines noueuses :
nodosités sur racines

.ផ្សិតបង្កអោយមានប្រជ្រុយស្លឹក: Alternaria Leaf Spot

បង្កឡើងដោយមេរោគឈ្មោះ Alternaria Cucumerina

.ជម្ងឺខ្មៅស្លឹក និងដើម: Gummy Stem Bleght

បង្កដោយមេរោគឈ្មោះ Dedymella bryoniae



Oïdium : taches sur feuilles

-ជម្ងឺផ្សិតលើដើម និងស្លឹកៈ ជម្ងឺនេះច្រើនកើតនៅចុងរដូវភ្លៀង



Fusariose sur tige de melon : gouttes de gomme

-ជម្ងឺស្វួតស្លឹក ឫស និងដើម Fusarium wilt



Fusariose du melon :
nécrose de la tige

-វិធានការការពារ និងកំចាត់:

. យកគ្រាប់ពូជទៅត្រាំទឹកក្តៅកំដៅ ៥00C រយ:ពេល ១៥-២0 នាទី

. ដុះបានរយ:ពេល៥-៧ថ្ងៃ យកថ្នាំសំលាប់ផ្សិតដូចជា: Zined Mancozed Captan ចំនួន ២0ក្រ. លាយទឹក ១៥ លីត្របាញ់អោយជោគទៅលើកូនឪឡឹកខ្ចីៗ

. ជៀសវាងដាំលើដីដែលដាំដំណាំអំបូរនេះដដែលៗ

-ជម្ងឺដែលបង្កឡើងដោយបាក់តេរីៈ

.បាក់តេរីធ្វើអោយស្រពោនៈ Bacterial Wilt

បង្កដោយមេរោគឈ្មោះ  Erwina tracheiphila

.បាក់តេរីបង្កអោយខ្លោចស្លឹក និងដើមៈ Bacterial Spot

មេរោគនេះឈ្មោះ Pseudomonas  Saringae  pv. lachrymans



Chancre à Didymella

## .ជម្ងឺរលួយប្រព័ន្ធឫសពណិស្វាយ



Dépérissement du concombre

- **វិធានការការពារ និងព្យាបាល**
- ប្រើប្រាស់ថ្នាំក្លរ៉ូណែប Chloroneb លាយជាមួយគ្រាប់នៅពេលរក្សាទុក
- ពេលកើតជម្ងឺក្រោយពីដាំគេប្រើថ្នាំ Benomyl Dinocap, Thinophanat

# ជម្ងឺបណ្តាលមកពីណេម៉ាតូត

-ជម្ងឺពកឫសណេម៉ាតូតនេះបណ្តាលមកពីមេរោគឈ្មោះ Meloidogyne spp



**Meloidogyne :**
*galles sur racines de melon*

# វិធានការការពារ

- ដាំដំណាំបង្វិល
- ភ្ជួរដីអោយជ្រៅអាចកាត់បន្ថយចំនួនណេម៉ាតូតនៅក្នុងដី
- បំផ្លាញជំរកស្មៅចង្រៃ
- បំបៅនៅលើប្រព័ន្ធឫសនៅផ្នែកខាងលើដែលធន់នឹងជម្ងឺ
- ជីធម្មជាតិធ្វើយ៉ាងណាឱ្យមានប្រតិកម្មចប់ល្អ

- ការប្រមូលផល

.ត្រូវសំគាល់ទៅលើអង់តែងទាំងពីរអមទងផ្លែ កាលណាវាស្ងួត ៧0% ពីខាងចុងទៅគល់

.សំបកនៃផ្លែមានក្រាមម្សៅក្រាស់

.ប្រើកំបិត ឬ កន្ត្រៃកាត់ផ្តាច់ទងហើយជញ្ជូនយកទៅរក្សាទុកកន្លែងត្រជាក់

-ប្រភេទពូជស្រាលមានអាយុកាលពី ៥៥-៦០ ថ្ងៃ

-ពូជកណ្តាលពី  ៦៥-៧៥ ថ្ងៃ

-ពូជធ្ងន់ពី  ៨០-៩០ ថ្ងៃ  ក្រោយពេលដាំ

-ទិន្នផលជាមធ្យមពី ១៥-១៧ តោនក្នុងមួយហិចតា  ។

# សូមអរគុណ